ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គិសនីកម្ពុជា
គណៈកម្មាធិការលទ្ធកម្ម
លេខ: 2174..... PEAC.អក

# សេចក្តីជូនដំណឹង
## ស្តីពី

ការអញ្ជើញចូលរួមដេញថ្លៃ ថ្លៃឯកតាក្នុងការផ្គត់ផ្គង់សម្ភារនិងឈ្នួលពលកម្មសាងសង់ហេដ្ឋារចនាសម្ព័ន្ធអគ្គិសនី ក្រោមកម្មវិធីផ្តល់ការផ្គត់ផ្គង់អគ្គិសនីសម្រាប់បូមទឹកធ្វើកសិកម្ម នៅ ខេត្តបាត់ដំបង ពោធិ៍សាត់ តាកែវ កណ្តាល ព្រៃវែង និងកំពង់ធំ

អគ្គិសនីកម្ពុជាសូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាអោយបានជ្រាបថា អគ្គិសនីកម្ពុជានឹងដាក់ឱ្យដេញថ្លៃជាសាធារណៈដើម្បីជ្រើសរើសអ្នកទទួល ថ្លៃឯកតាក្នុងការផ្គត់ផ្គង់សម្ភារនិងឈ្នួលពលកម្មសាងសង់ហេដ្ឋារចនាសម្ព័ន្ធអគ្គិសនី ក្រោមកម្មវិធីផ្តល់ការផ្គត់ផ្គង់អគ្គិសនីសម្រាប់បូមទឹកធ្វើកសិកម្ម នៅ ខេត្តបាត់ដំបង ពោធិ៍សាត់ តាកែវ កណ្តាល ព្រៃវែង និងកំពង់ធំ ។

អគ្គិសនីកម្ពុជាបានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ ។ ឯកសារដេញថ្លៃ មានដាក់លក់នៅអង្គភាពលទ្ធកម្មអគ្គិសនីកម្ពុជាដែលមានអាសយដ្ឋាន អាគារលេខ ២ ផ្លូវព្រះយុគន្ធរ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ ចាប់ពី ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៧ តទៅរៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ៖ 023 67 66 007 និង Website : www.edc.com.kh ) ។

ឯកសារដេញថ្លៃដែលបានបំពេញរួច ត្រូវប្រគល់ជូនអង្គភាពលទ្ធកម្ម យ៉ាងយូរបំផុតត្រឹម ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៧ វេលាម៉ោង ១៤:00 ។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋាន ខាងលើ វេលាម៉ោង ១៥:00 ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៧ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។ (

រាជធានីភ្នំពេញ , ថ្ងៃទី 13 ខែ កញ្ញា ឆ្នាំ ២០១៧
**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

**ឆឹង_អ៊ឹង**

ចម្លងជូន ៖
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ
-ឯកសារ-កាលប្បវត្តិ